YUNNAN DAILY PRESS GROUP
No.206

ប្រទេសចិន-ខេត្តយូនណាន

ភ្នំពេញប្រៃសណីយ៍

klunerlight@163.com
yunnangateway.com
Follow Amazing Yunnan on Facebook

ឆ្នាំទី27 លេខ8113 ថ្ងៃសុក្រ ទី27 ខែធ្នូ ឆ្នាំ2019

ខេត្តយូនណានគម្រោងរថភ្លើងល្បឿនលឿននាំមកនូវក្តីសង្ឃឹមថ្មី



នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៩រថភ្លើងល្បឿនលឿនមួយ គ្រឿងធ្វើដំណើរឆ្លងកាត់ស្ពានធំទន្លេស៊ីស៊ា តាមខ្សែរថភ្លើងល្បឿនលឿន ឈីងទូ-គួយយ៉ាង

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០១៩ កំណាត់នៅខេត្តយូនណាននៃខ្សែរថភ្លើងឈុងឈីង-គុនមីង ដែលជាផ្នែកសំខាន់មួយនៃបណ្តាញខ្សែរថភ្លើងល្បឿនលឿនចិនបានបើកការដ្ឋានសាងសង់ជាផ្លូវការ ។ ក្រោយពីបញ្ចប់ការសាងសង់ជាស្តាពរនូវខ្សែរថភ្លើងនេះរយៈពេលនៃការធ្វើដំណើរពីក្រុងគុនមីងទៅក្រុងឈុងឈីងនិងឈីងទូនឹងត្រូវកាត់បន្ថយពី៥-៦ម៉ោងដល់ទៅប្រមាណ ២ម៉ោង ។ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០១៩ទន្ទឹមនឹងការដាក់ឱ្យប្រើប្រាស់នូវខ្សែរថភ្លើងល្បឿនលឿនឈីងទូ-គួយយ៉ាងក្រុងចោធុងដែលស្ថិតនៅភាគខាងជើងនៃខេត្តយូនណានបានកែប្រែស្ថានភាពដែលគ្មានរថភ្លើងល្បឿនលឿនក្នុងប្រវត្តិសាស្ត្រ ។ ខ្សែរថភ្លើងល្បឿនលឿនឈីងទូ-គួយយ៉ាងចាប់ផ្តើមពីក្រុងឈីងទូនៃខេត្តស៊ីឈួនឆ្លងកាត់ស្រុកជីនស្យូងនិងស្រុកវៃស៊ីននៃក្រុងចោធុងខេត្តយូនណានរហូតដល់ក្រុងគួយយ៉ាងនៃខេត្តគួយចូវ ។ ខ្សែរថភ្លើងនេះមានប្រវែងសរុប៦៤៨គីឡូម៉ែត្រ ។ រថភ្លើងអាចធ្វើដំណើរក្នុងល្បឿន២៥០គីឡូម៉ែត្រ/ម៉ោងតាមផ្លូវរថភ្លើងនេះ ។

សព្វថ្ងៃខេត្តយូនណាន ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ភ្នំនៅភាគខាងលិចប្រទេសចិននោះ បានត្រូវតភ្ជាប់ទៅនឹងខេត្តក្រុងផ្សេងៗនៃប្រទេសចិនតាមបណ្តាញខ្សែរថភ្លើងល្បឿនលឿន។ ស្រុកជីនស្យូងដែលបានបង្កើតខ្សែរថភ្លើងល្បឿនលឿននោះ មានប្រជាជនជាងមួយលាននាក់ ហើយជាស្រុកដែលមានប្រជាជនច្រើនជាងគេក្នុងខេត្តយូនណាន ។ ស្រុកវៃស៊ុនស្ថិតនៅតាមទីប្រសព្វគ្នានៃខេត្តយូនណានគួយចូវ និងស៊ីឈួន ។ ស្រុកទាំងពីរនេះសុទ្ធតែជាស្រុកក្រីក្រដែលមានលក្ខខណ្ឌមិនអំណោយផលដល់ការធ្វើដំណើរ ។ ខ្សែរថភ្លើងល្បឿនលឿននឹងផ្តល់ការងាយស្រួលដល់អ្នកស្រុកក្នុងការធ្វើដំណើរទៅមកព្រមទាំងជួយកាត់បន្ថយភាពក្រីក្រនិងផ្តល់កាលានុវត្តភាពដល់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ ។

ឆ្លងតាមរយៈការសាងសង់អស់ពេលជាច្រើនឆ្នាំខ្សែរថភ្លើងល្បឿនលឿនបានជំរុញឱ្យមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅខេត្តយូនណាន ។ ខេត្តយូនណានបានសាងសង់ផ្លូវរថភ្លើងកាន់តែច្រើននិងគ្របដណ្តប់លើផ្ទៃដីកាន់តែធំទូលាយដែលបានតភ្ជាប់ខេត្តក្រុងសំខាន់ចំនួន១៩ នៃប្រទេសចិន ។ អ្នកដំណើរអាចជិះរថភ្លើងល្បឿនលឿនពីខេត្តយូនណានទៅខេត្តក្រុងទាំងនោះហើយប្តូររថភ្លើងទៅក្រុងផ្សេងៗទៀតនៃប្រទេសចិន។ សព្វថ្ងៃអ្នកដំណើរអាចជិះរថភ្លើងល្បឿនលឿនដើម្បីធ្វើដំណើរទៅមករវាងក្រុងផ្សេងៗនៅភូមិភាគកណ្តាលខេត្តយូនណានដោយចំណាយពេលតែមួយម៉ោងហើយទៅដល់ទីក្រុងជាទីរួមខេត្តនៃខេត្តជុំវិញដោយចំណាយពេលពី២ ដល់ ៥ ម៉ោង ។

ទន្ទឹមនឹងការសាងសង់ខ្សែរថភ្លើងល្បឿនលឿនឈុងឈីង-គុនមីង និងគម្រោងរថភ្លើងល្បឿនលឿនផ្សេងៗទៀត លក្ខខណ្ឌគមនាគមន៍នៃខេត្តយូនណាននឹងអាចត្រូវកែលម្អជាបន្តបន្ទាប់ ។ ក្តីសង្ឃឹមអំពីការសាងសង់ខ្សែរថភ្លើងល្បឿនលឿននៅស្រុកកំណើតរបស់ខ្លួនបានក្លាយទៅជាបញ្ហាក្តៅគគុកដែលទទួលការចាប់អារម្មណ៍ពីប្រជាជនចិនគ្រប់ៗគ្នាតាមបណ្តាញអ៊ីនធឺណិត ៕

ឯកឧត្តមស៊ី ជីនភីង បកស្រាយពីគោល-នយោបាយ "ប្រទេសមួយប្រព័ន្ធពីរ"

ក្នុងដំណើរនៃការអនុវត្តន៍គោលនយោបាយ"ប្រទេសមួយប្រព័ន្ធពីរ"សាលាតំបន់រដ្ឋបាលពិសេស និងគ្រប់មជ្ឈដ្ឋានក្នុងសង្គមខិតខំបង្រួបបង្រួមនូវការថែរក្សាអធិបតេយ្យភាពជាតិការថែរក្សាសន្តិភាពជាតិនិងការអភិវឌ្ឍផលប្រយោជន៍ប្រទេសជាមួយការជំរុញវិបុលភាពនិងការថែរក្សាស្ថិរភាពរយៈពេលវែងនៃតំបន់ម៉ាកាវមានអន្ទះដ៏មោះមុតហើយមិនប្រែចិត្តនៅពេលមានរបត់រយៈពេលណាមួយមិនរង្វេងនៅពេលទទួលការរំខានពីខាងក្រៅ មានសមត្ថភាពដ៏ខ្លាំងក្លាដើម្បីក្តាប់ឱ្យជាប់នូវកាលានុវត្តភាពដែលនាំមកដោយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសំខាន់ៗនិងគោលនយោបាយផ្សេងៗ ដើរឆ្ពោះទៅមុខតាមនិន្នាការអភិវឌ្ឍសម្រេចបាននូវការអភិវឌ្ឍកាន់តែល្អប្រសើររបស់ខ្លួនក្នុងដំណើរនៃការចូលរួមនិម្មាបនកម្មអភិវឌ្ឍន៍ទូទៅនៃប្រទេសជាតិ ៕

(ដកស្រង់ចេញពីសុន្ទរកថា របស់ឯកឧត្តមស៊ីជីនភីងដែលថ្លែងក្នុងពិធីអបអរសាទរខួបលើកទី២០ឆ្នាំនៃការត្រឡប់មកមាតុប្រទេសវិញរបស់តំបន់ម៉ាកាវនៅថ្ងៃទី២០ខែធ្នូឆ្នាំ២០១៩)

សិប្បកម្មលើចុងកាំបិត:សិប្បកម្មចម្លាក់ឈើនៅក្រុងភូអីខេត្តយូនណាន

ចម្លាក់ឈើនៅក្រុងភូអីនៃខេត្តយូនណានជាសិប្បកម្មពិសេសម៉្យាងដែលមានស្នាមចម្លាក់ដូចគំនូរឆ្នាក់ និងប្រកបដោយសម្រស់ស្អាតនៃស្នាមឆ្នាក់ ហើយក៏មានលក្ខណៈពិសេសនៃគំនូរដែរ ។ សិប្បកម្មដ៏លំបាកលំបិននេះ បានទទួលការពេញនិយមពីសំណាក់ ប្រជាជនគ្រប់ៗគ្នា ។ ប៉ុន្មានឆ្នាំនេះ វិទ្យាស្ថានភូអីខិតខំជំរុញការទទួលបន្ត និងផ្សព្វផ្សាយពីសិប្បកម្មប្រពៃណីនេះហើយបានបណ្តុះបណ្តាលសិក្ខាកាមរាប់រយនាក់ហើយ។

ចម្លាក់ឈើក្រុងភូអីជាសិប្បកម្មឆ្នាក់លេចធ្លោមួយប្រភេទដែល វិវឌ្ឍន៍ពីសិប្បកម្មចម្លាក់ឈើដែលមានលក្ខណៈប្រពៃណី។ សិប្បកម្មនេះប្រភពដើមពីក្រុងភូអី ខេត្តយូនណាននៅ ទសវត្សរ៍ឆ្នាំ៨០ នៃសតវត្សរ៍មុន ។ ក្រោយពីបានអភិវឌ្ឍន៍ជាង៣០ឆ្នាំសិប្បកម្មចម្លាក់ឈើនេះបានក្លាយទៅជាផ្នែកសំខាន់មួយក្នុងចំណោមគំនូរ ចម្លាក់ល្បីទាំង៤នៃប្រទេសចិន ៕

ដោយហ្វី អាវ(ស៊ីនហួចិន)

ក្នុងរោងសិប្បកម្ម នៃវិទ្យាស្ថានភូអីនិស្សិតផ្នែកសិល្បៈកំពុងធ្វើវត្ថុចម្លាក់ឈើ

នៅឆ្នាំ២០១៩ប្រទេសចិននឹងកាត់បន្ថយជនក្រីក្រជាង១០លាននាក់

ស្រុកជីននីងនៃ ក្រុងគុនមីងអភិវឌ្ឍន៍មុខរបរផ្កាស្រស់ ពិសេសដើម្បីដឹកនាំប្រជាជនចូលរួម ក្នុងការកាត់បន្ថយភាពក្រីក្រ

នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០១៩ ឯកឧត្តមលីវ ឃ្លុងហ្វ ប្រធានការិយាល័យកាត់បន្ថយភាពក្រីក្រនៃក្រុមប្រឹក្សាកិច្ចការរដ្ឋចិន បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី៤ នៃសមាគមអ្នកស្ម័គ្រចិត្តកាត់បន្ថយភាពក្រីក្រចិនអាណត្តិទី១ ។ ឯកឧត្តមមានប្រសាសន៍ថាតាមការព្យាករណ៍ នៅឆ្នាំ ២០១៩ ប្រទេសចិននឹងកាត់បន្ថយជនក្រីក្រជាង១០លាននាក់ ។ គិតមកដល់ចុងឆ្នាំ ២០១៩ប្រជាជនក្រីក្រជាង៩៥ភាគរយនឹងអាចរួចខ្លួនចេញពីភាពក្រីក្រ ចំណែកស្រុកក្រីក្រជាង៩០ភាគរយនឹងទទួលការជោគជ័យក្នុងការកាត់បន្ថយភាពក្រីក្រ ។

តាមស្ថិតិក្នុងអំឡុងពេលពីឆ្នាំ ២០១៣ដល់ឆ្នាំ២០១៨ ចំនួនប្រជាជនក្រីក្ររបស់ប្រទេសចិនបានត្រូវកាត់បន្ថយពី៩៨,៩៩លាននាក់ដល់ទៅ ១៦,៦លាននាក់ ។ គិតជាមធ្យមប្រទេសចិនបានកាត់បន្ថយជនក្រីក្រជាង១២ លាននាក់ជារៀងរាល់ឆ្នាំ ។ ក្នុងចំណោមស្រុកក្រីក្រចំនួន៨៣២ នៃប្រទេសចិន មានស្រុកចំនួន៤៣៦ បានកាត់បន្ថយភាពក្រីក្រ ។ រឿងរ៉ាវនិងសមិទ្ធផលអំពីការកាត់បន្ថយភាពក្រីក្រនៃប្រទេសចិនបានទទួលការចាប់អារម្មណ៍ពីពិភពលោកទាំងមូល ។

នៅដើមខែវិច្ឆិកា អ្នកភូមិ ឈ្មោះ តឹង ស្បៀស៊ឹងដែលរស់នៅក្នុងក្រុមឈើកីសាំងភូមិជ្ងស្បៀង ឃុំយ៉ុងឈុន ស្រុកស្វយ័តជនជាតិលីស៊ូវីស៊ី មណ្ឌលស្វយ័តជនជាតិទីបេត៍ទីឈីង ខេត្តយូនណាននិយាយគ្នាលេងជាមួយញាតិមិត្តក្នុងផ្ទះរបស់លោក ។ មានមនុស្សម្នាក់សួរអ្នកផ្សេងថា"អ្នកទាំងអស់គ្នាយទាយមើល៍ក្រោយពីអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រដោយតម្រង់ទិស តើយើងមានរបស់អ្វីកាន់តែច្រើនឡើង?"អ្នកផ្សេងក៏ឆ្លើយភ្លាមៗថា"សេះល្អ" ។ គេទាំងអស់គ្នាសប្បាយខ្លាំងណាស់ ។ ប៉ុន្មានឆ្នាំនេះស្រុកវីស៊ីប្រើបច្ចកម្មវិធីជ្រើសរើស"ពានរង្វាន់សេះល្អ"និង"ពានរង្វាន់"ផ្សេងៗទៀត ផ្តោតសំខាន់ទៅលើការកសាងឃុំស្អាតជាងគេភូមិស្អាតជាងគេគ្រួសារដែលមានសុភមង្គលជាងគេនិងគំរូល្បីជាងគេ ដើម្បីជំរុញឱ្យស្រុកវីស៊ីក្លាយទៅជា"តំបន់ភ្នំនឹងទឹកស្រុកសុភមង្គល" ដែលសក្តិសមនឹងការរស់នៅដើរលេងកម្សាន្តបង្កើតមុខជំនួញនិងថែរក្សាសុខភាពហើយបានផ្សព្វផ្សាយពីការប្រើបច្ចកម្មវិធីជ្រើសរើស"ពានរង្វាន់"ទៅដល់គ្រប់ភូមិដើម្បីបង្កើនកម្លាំងចលករផ្ទៃក្នុងរបស់មហាជនសម្រាប់ការកាត់បន្ថយភាពក្រីក្រ ។

អ្នកភូមិឈ្មោះលួ ហុងម៉ែង ដែលមានអាយុ ៤៦ឆ្នាំ រស់នៅក្នុងភូមិហួងប៉េឃុំស្បៅវហ្គឺ ស្រុកលីវយ៉ាង ខេត្តហ៊ូណាន ។ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០១៩ ក្រុមហ៊ុនផលិតគ្រឿងបរិភោគក្នុងតំបន់ឧស្សាហកម្មស្រុកលីវយ៉ាងបានប្រមូលទិញបន្លែរបស់លោក។ លោកបានប្រាប់អ្នកការសែតដោយមានភាពសប្បាយរីករាយថា ខ្ញុំអាចទទួលបានចំណូល ២,៧ម៉ឺនយ៉ាន់ពីការដាំបន្លែ បើគិតបញ្ចូលនូវចំណូលដែលទទួលបានពីការដាំសណ្តែកគ្រួសារខ្ញុំអាចទទួលបានចំណូលជាង៥ម៉ឺនយ៉ាន់ក្នុងឆ្នាំនេះ ។

ក្រុមហ៊ុនផលិតគ្រឿងបរិភោគត្រូវទិញវត្ថុធាតុដើមដ៏ច្រើន ហើយបាននិងកំពុងដើរតួនាទីសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ។ រូបមន្ត"សហគ្រាស+សហករណ៍+គ្រួសារក្រីក្រ"បានជំរុញការអនុវត្តន៍គោលនយោបាយកាត់បន្ថយភាពក្រីក្រតាមរយៈការអភិវឌ្ឍមុខរបរថ្មីនិងការផ្តល់ការងារធ្វើដល់ប្រជាជនហើយបាននាំឱ្យគ្រួសារក្រីក្រដ៏ច្រើនធ្វើដំណើរតាមផ្លូវកាត់បន្ថយភាពក្រីក្រនិងដើរឆ្ពោះទៅកាន់ជីវភាពធូរធារ ៕

តំបន់ម៉ាកាវរៀបចំកម្មវិធី ហែក្បួនចម្រុះពណ៌អន្តរជាតិដើម្បីអបអរសាទរខួបលើកទី២០ឆ្នាំនៃការត្រឡប់មកមាតុប្រទេសវិញ

ពេលថ្មីៗនេះ កម្មវិធីហែក្បួនចម្រុះពណ៌អន្តរជាតិឆ្នាំ២០១៩ បានរៀបចំនៅតំបន់ម៉ាកាវនៃប្រទេសចិន។ សិល្បៈករសិល្បការិនីម៉ាកាវនិងក្រុមសិល្បៈដែលមកពីបណ្តាប្រទេសនានាតាមបណ្តោយ"ខ្សែក្រវាត់មួយ និងផ្លូវមួយ"បានរួមគ្នាចូលរួមកម្មវិធីនេះ ដើម្បីអបអរសាទរខួបលើកទី២០ឆ្នាំនៃការត្រឡប់មកមាតុប្រទេសវិញរបស់តំបន់ម៉ាកាវ ។

កម្មវិធីហែក្បួននេះ រៀបចំក្រោមប្រធានបទពិសេសអំពី"វប្បធម៌នៃប្រទេសនិងតំបន់ខ្សែក្រវាត់និងផ្លូវ" ។ ក្រុមសិល្បៈដែលមកពីប្រទេសនិង តំបន់"ខ្សែក្រវាត់មួយនិងផ្លូវមួយ"ចំនួន ១៦ រួមមានប្រទេសអ៊ុយក្រែនប៉ូឡូញនិងអ៊ីតាលីជាដើមបានចូលរួមក្នុងកម្មវិធីនេះ ។ ក្រុមហែក្បួនម៉ាកាវក៏បានសម្តែងកម្មវិធីពិសេសដែលមានពាក់ព័ន្ធទៅនឹងវប្បធម៌ និងរឿងរ៉ាវនៃប្រទេស"ខ្សែក្រវាត់មួយនិងផ្លូវមួយ" ។ ក្នុងឱកាសខួបលើកទី២០ឆ្នាំនៃការត្រឡប់មកប្រទេសចិនវិញតំបន់ម៉ាកាវបានរៀបចំពិព័រណ៍វត្ថុបុរាណពិព័រណ៍គំនូរ និងពិព័រណ៍ផ្កាស្រស់ជាដើម ដើម្បីសម្តែងនូវមនោសញ្ចេតនាស្នេហាជាតិនិងសម្លឹងមើលទៅអនាគតដ៏ភ្លឺស្វាងនៃតំបន់ម៉ាកាវ ៕ **(ស៊ីនហួចិន)**